

# ធ្វើការជាមួយអ្នកដែលត្រូវបានគេយកចិត្តទុកដាក់តិចតួច

*ការអប់រំ មានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការអភិវឌ្ឍសង្គម និងធនធានមនុស្ស។ ការអប់រំក៏ជាសិទ្ធិមនុស្សមួយដ៏មានសារៈសំខាន់ផងដែរ ហើយកម្រិត និងផលប៉ះពាល់នៃការអប់រំ អាចកំណត់អនាគត និងលទ្ធភាពសម្រាប់កុមារ តាមរយៈវិធីជាច្រើន។ ក្នុងអំឡុងពេល២៥ឆ្នាំ ចុងក្រោយនេះ ប្រព័ន្ធអប់រំនៅកម្ពុជា ត្រូវបានស្ថាបនាឡើងវិញបន្ទាប់ពីត្រូវបានបំផ្លិចបំផ្លាញទាំងស្រុងក្នុងរបបប៉ុលពតនាទសវត្សឆ្នាំ១៩៧០។ ក្រៅពីរចនាសម្ព័ន្ធសាលារៀនទូរទៅ ក្រសួងអប់រំ យុវជន និងកីឡា ក៏បាននឹងកំពុងធ្វើការផ្សព្វផ្សាយអំពីសាលាមត្តេយ្យ ដើម្បីឲ្យកុមារទទួលបានការចាប់ផ្តើមរៀនសូត្រ និងការសិក្សាមួយដ៏ល្អសម្រាប់ពួកគេ។*

សាលាមត្តេយ្យ និងសាលាបឋមសិក្សា គឺស្ថិតនៅក្នុងផ្នែកមួយនៃចំណុចផ្តោចរបស់គម្រោង អាយស៊ីស៊ី ហ្វាស (អភិវឌ្ឍន៍គ្រួសារ និង សាលារៀន) នៅខេត្តស្វាយរៀង ចាប់តាំងពីឆ្នាំ២០១២មក។ គម្រោងហ្វាស បានសហការជាមួយនឹងគណៈកម្មការទ្រទ្រង់សាលា (គ.ទ.ស) (សូម មើលរូបភាពខាងលើ) ដើម្បីជួយដល់កុមារនៅក្នុងសហគមន៍ជនបទឲ្យទទួលបាននូវការអប់រំប្រកបដោយគុណភាពតាំងពីវ័យកុមារ។ រួមជាមួយគ្នា គ.ទ.ស និង គណៈកម្មាធិការសាលាមត្តេយ្យ ឥឡូវនេះកុមារត្រូវបានទទួលបានការអប់រំកាន់តែប្រសើរឡើង ចាប់ពីអាយុ០៣ឆ្នាំរហូតដល់០៥ឆ្នាំ តាមរយៈការ ចូលរៀននៅតាមសាលាមត្តេយ្យសហគមន៍ចំនួន១១ដែលត្រូវបានបង្កើតឡើងនៅតាមតំបន់ជនបទនៅក្នុងខេត្ត។ បច្ចុប្បន្ននេះសាលាមត្តេយ្យចំនួន០៣ទៀត កំពុងត្រូវបានសាងសង់ឡើងជាមួយនឹងមូលនិធិដែលប្រមូលបានតាមរយៈ គ.ទ.ស។

បច្ចុប្បន្ននេះ សាលាបឋមសិក្សាចំនួនពីរ ត្រូវបានទទួលស្គាល់ដោយក្រុមប្រឹក្សាឃុំ/សង្កាត់ និងការិយាល័យអប់រំ យុវជន និងកីឡា ថ្នាក់ស្រុក ក្នុងការបំពេញបានតាមគ្រប់សូចនាករចំនួន៣៣ នៃ "ស្តង់ដាអប្បបរមា មតេយ្យសហគមន៍" ដែលត្រូវបានកំណត់ឡើងដោយក្រសួងអប់រំ យុវជន និងកីឡា។ គម្រោងហ្វាស និង គ.ទ.ស កំពុងធ្វើការយ៉ាងសកម្ម ដើម្បីធ្វើឲ្យសាលាមត្តេយ្យសហគមន៍ដ៏ទៃទៀតបានបំពេញតាមគ្រប់សូចនាកស្តង់ដាអប្បបរមាដែលត្រូវបានកំណត់នេះផងដែរ ដើម្បីទទួលបានការទទួលស្គាល់ដូចគ្នាពីអាជ្ញាធរ ប៉ុន្តែអ្វីដែលសំខាន់បំផុតនោះ គឺដើម្បីផ្តល់ការអប់រំដ៏មាន ប្រសិទ្ធភាពទៅដល់កុមារ ក៏ដូចជាចំណេះដឹងចាំបាច់ផ្សេងៗទៀតសម្រាប់អនាគតរបស់ពួកគេ។

លើសពីនេះទៀតនោះ ក្នុងចំណោមសាលាបឋមសិក្សាចំនួន៥ដែល គ.ទ.ស និងគម្រោងហ្វាស បាននឹងកំពុងធ្វើការជាមួយគឺ សាលាបឋមសិក្សាចន្ទ្រា គឺជាសាលាគំរូមួយដែលត្រូវបានទទួលលិខិតកោតសរសើរពីក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការដឹកនាំ និងការប្រាស្រ័យទាក់ទងដ៏ល្អជាមួយនឹងសហគមន៍ក្នុងការកែលម្អសាលារៀន។ សាលាបឋមសិក្សាចំនួន៥ ដែលស្ថិតនៅក្នុងគោលដៅរបស់គម្រោងហ្វាស ៩៥-៩៨ភាគរយនៃចំនួនសិស្សសរុបត្រូវបានជាប់មធ្យមភាគ ហើយមានសិទ្ធិក្នុងការបន្តការសិក្សាទៅថ្នាក់លើទៀត។

ទោះបីជាភាពជោគជ័យបានកើតឡើងច្រើនតាមរយៈកិច្ចសហការរវាងគម្រោងហ្វាង ជាមួយនឹង គ.ទ.ស ក៏ដោយប៉ុន្តែបញ្ហាប្រឈមនៅតែកើតមានឡើង។ បញ្ហាប្រឈមមួយ គឺទាក់ទងទៅនឹងកង្វះខាតសម្ភារៈសម្រាប់សាលារៀនដោយសារតែសាលាមត្តេយ្យភាគច្រើន គឺស្ថិតនៅតាមផ្ទះរបស់គ្រូបង្រៀនផ្ទាល់។ បញ្ហាប្រឈមមួយទៀត គឺកង្វះខាត់គ្រូបង្រៀនដោយសារតែបញ្ហាប្រាក់ខែតិច។ គម្រោងហ្វាស ស្វះស្វែងសម្របសម្រួលឲ្យមានកិច្ចសហប្រតិបត្តិការកាន់តែប្រសើរឡើងរវាង គ.ទ.ស និងអាជ្ញាធរមូលដ្ឋាន ហើយជាលទ្ធផលអាជ្ញាធរឃុំបានបង្កើនប្រាក់ខែគ្រូបង្រៀនសាលាមត្តេយ្យសហគមន៍ពី៣០ដុល្លារដល់៥០ដុល្លារក្នុងមួយខែ។ ដូច្នេះហើយ ទើបគ្រូបង្រៀននៅក្នុងឃុំទាំងនោះបានសំរេចចិត្តក្នុងការបន្តបង្រៀនដល់កុមារ នៅក្នុងសហគមន៍។

*កាលបរិច្ឆេទ ៖ ឧសភា ២០១៨*